# ព្រះស្កន្ទក្នុងគំនិតខ្មែរបុរាណ

***ស្កន្ទ*** (Skanda) ជាព្រះនាមមួយក្នុងចំណោមព្រះនាមទាំង១០៨របស់ព្រះស្កន្ទ ដែលជាពាក្យក្នុងភាសាសំស្ក្រឹតប្រែថា "***លោត, វាយប្រហារ, ផ្ទុះ, កំពប់, វិនាស***" ហើយព្រះនាមសំខាន់ៗផ្សេងទៀតដែលគេស្គាល់ទេពអង្គនេះ ដែលមានដូចជា កុមារ (Kumãra) កាត្តិកេយ (Kãrtikeya) មុរុគន (Murugana) សុព្រហ្មន្យ (Subrahmanya)។[១]

នៅក្នុងទេវកថាព្រហ្មញ្ញសាសនា គេចាត់ទុកទេពអង្គនេះ ជាទេពនៃសង្គ្រាម ឬជាមេទ័ពប្រចាំនៅស្ថានសួគ៌ ត្រូវជាបុត្ររបស់ព្រះឥសូរ និងព្រះនាងបវ៌តី ដែលមានយានជំនិះជាសត្វក្ងោក មានព្រះសិរមួយនិងប្រាំមួយ ព្រះហស្តកាន់ធ្នូ ដាវ រន្ទះ ពូថៅ លំពែង។ រឿងនិទានទាក់ទងនឹងព្រះស្កន្ទមានច្រើនគម្ពីរណាស់ ហើយសាច់រឿងខ្លះផ្សេងៗពីគ្នាទៅតាមការរៀបរាប់របស់គម្ពីរនីមួយៗ។ ជាក់ស្តែងតាមកំណាព្យរបស់កុមារសម្ភវ (Kumãrasambhava) និទានថា[២]៖ "*មានអសុរមួយឈ្មោះថា "តារក" (Taraka) មានអំណាចនិងវេទមន្តខ្លាំងពូកែ ដ្បិតអសុរនេះបានទទួលពរពីព្រះឥសូរ។ អសុរនេះ បានដើរអុកឡុកកក្រើកស្ថានទាំងបី ក្នុងពេលដែលព្រះឥសូរកំពុងតាំងសមាធិ។ គ្មាននរណាអាចសម្លាប់អសុរនេះបានក្រៅពីថាមពលអំណាចរបស់ព្រះឥសូរឡើយ ពោល គឺបុត្ររបស់ព្រះឥសូរ។ ដោយមានកង្វល់ពីការអុកឡុករបស់អសុរនេះ អាទិទេពនៅស្ថានសួគ៌បានបញ្ជាឱ្យនាងបវ៌តីដែលជានារីមានចិត្តចង់រៀបអភិសេកជាមួយព្រះឥសូរ ចូលទៅលួងលោមព្រះឥសូរឱ្យរៀបអភិសេកនឹងខ្លួន និងក្នុងបំណងឱ្យព្រះឥសូរបោះបង់ការតាំងសមាធិទៅបង្ក្រាបបិសាចតារក។ ទោះបីជានាងបវ៌តីបានលួងលោមទ្រង់យ៉ាងក្តី ក៏ព្រះឥសូរមិនអើពើ និងបន្តតាំងសមាធិ។ អាទិទេព ក៏បានបញ្ជូនព្រះកាមទេព ដែលជាទេពនៃសេចក្តីស្នេហា ទៅលបបាញ់ព្រួញកាមទេពទៅព្រះឥសូរ ហើយព្រួញនោះបានបាញ់ចំព្រះឥសូរដូចប្រាថ្នា។ ក្នុងពេលនោះ ព្រះឥសូរខឹងយ៉ាងខ្លាំងក៏បានប្រើព្រះនេត្រទីបីដុតព្រះកាមឱ្យរលាយក្លាយជាផេះផង់រហូតមក។ បន្ទាប់មកព្រះឥសូរក៏ព្រមរៀបអភិសេកជាមួយនាងបវ៌តី ប៉ុន្តែទ្រង់មិនអាចផ្តល់មេជីវិតដល់នាងបវ៌តីដើម្បីបង្កើតបុត្របានទេ ដោយហេតុថាទឹកកាមរបស់ទ្រង់មានអំណាចនិងក្តៅខ្លាំងដោយសារទ្រង់តមសោយអាហារយូរឆ្នាំក្នុងអំឡុងពេលតាំងសមាធិ។ អាទិទេព ក៏បញ្ជាឱ្យព្រះអគ្គីជួយអន្តរាគមន៍*

---

[១]Fred 1978; Roveda 2005.

[២]Fred 1978; Vanita & Kidwi 2001.

រឿងនេះៗ ព្រះអគ្នីបានទទួលទឹកកាមព្រះឥសូរដាក់លើបាតដៃ យកទៅទម្លាក់ចូលក្នុងបឹងមួយ ហើយទឹកកាមនោះក៏ចាប់កំណើតជាព្រះស្កន្ទឡើង និងបានទៅកម្ចាត់អសុរតារកដូចក្តីបំណង។

នៅសម័យបុរាណ ខ្មែរមានជំនឿទៅលើព្រះស្កន្ទមុតមាំខ្លាំងណាស់ ដ្បិតយើងដឹងស្រាប់ហើយ ទ្រង់ជាបុត្រព្រះឥសូរ ហើយសង្គមខ្មែរសម័យបុរាណព្រះឥសូរមានឥទ្ធិពលធំធេងណាស់។ ជាក់ស្តែងនៅរវាងស.វ.ទី៦-៧ គេរកឃើញចម្លាក់ និងបដិមាព្រះស្កន្ទច្រើនណាស់ដូចជា ចម្លាក់ព្រះស្កន្ទឈរលើសត្វក្ងោកនៅសារមន្ទីរជាតិភ្នំពេញ (មិនស្គាល់ប្រភព) (រូបលេខ១-២), ចម្លាក់ព្រះស្កន្ទគង់លើក្ងោកមកពីទួលក្តីអង្គ (តាំងសារមន្ទីរហ្គីមេ) (រូបលេខ៣), ចម្លាក់ព្រះស្កន្ទគង់លើក្ងោកមកពីកំពង់ចាម (រូបលេខ៤), ព្រះស្កន្ទគង់លើក្ងោកនៅសារមន្ទីរកំពង់ធំ (រូបលេខ៥)។ ចំណែកនៅសម័យអង្គរវិញ ចម្លាក់ព្រះស្កន្ទក៏មានមិនច្រើនដែរ ហើយច្រើនសម្បូណ៌នៅស.វ.ទី១០-១១ ដូចជា ចម្លាក់ព្រះស្កន្ទឈរចាប់ព្រះហស្តព្រះឥសូរ (រូបលេខ៦), ព្រះស្កន្ទគង់លើក្ងោក មកពីប្រាសាទក្រចាប់ (រូបលេខ៧), ព្រះស្កន្ទឆ្លាក់នៅលើផ្តែរវត្តកកោះ (រូបលេខ៨), ព្រះស្កន្ទឆ្លាក់នៅលើផ្តែរប្រាសាទភិមាយ (រូបលេខ៩), ព្រះស្កន្ទឆ្លាក់រួមគ្នាជាមួយព្រះឥសូរជិះគោនៅពើងគំនូរ (រូបលេខ១០), ព្រះស្កន្ទ ឆ្លាក់រួមគ្នាជាមួយព្រះឥសូរជិះគោនៅពើងត្បាល់ចំនួនពីរទីតាំង (រូបលេខ១១)។ល។ ប្រការគួរកត់សម្គាល់ ពល់ចម្លាក់ព្រះស្កន្ទភាគច្រើនក្នុងសិល្បៈខ្មែរ សិល្បករច្រើនឆ្លាក់រូបព្រះស្កន្ទក្នុងទម្រង់ជាកុមារ (ក្មេងតូច) មានព្រះសិរត្រឹមតែមួយប៉ុណ្ណោះ លើកលែងចម្លាក់នៅពើងគំនូរដែលបង្ហាញទ្រង់មានព្រះសិរចំនួនប្រាំមួយ។ ចំពោះរឿងទេវកថាដែលនិទានទាក់ទងនឹងកំណើតព្រះសិរប្រាំមួយរបស់ព្រះស្កន្ទ ក៏មាននិទាននៅក្នុងគម្ពីរជាច្រើនដែរ ហើយសាច់រឿងនីមួយៗក៏ខុសគ្នាតាមនោះដែរ។ រឿងមួយនិទានថា៖ "កាត៌ិកេយ (ស្កន្ទ) ជាបុត្ររបស់ព្រះអគ្នីមានម្តាយចំនួន៦នាក់ ហើយអ្នកទាំង៦នាក់តែងតែឈ្លោះប្រកែកដណ្តើមគ្នាមើលថែទាំ និងបំបៅដោះព្រះកាត៌ិកេយ។ ដើម្បីបញ្ចប់ជម្លោះ ព្រះកាត៌ិកេយក៏ដប់ឱ្យមានព្រះសិរចំនួន៦ ដើម្បីឱ្យម្តាយទាំងប្រាំមួយនាក់ស្រួលមើលថែទាំទ្រង់"។[៣] ចំណែក រឿងមួយទៀតនិទានថា៖ ព្រះអគ្និបានលួចព្រះទ័យប្រតិព័ទ្ធប្រពន្ធចំនួន៦នាក់របស់ឥសីម្នាក់ឈ្មោះថា "អង្គិរស" ហើយក៏បានចូលសុំស្នេហា តែពួកនាងមិនព្រមស្រឡាញ់ឡើយ ព្រោះនាងស្មោះស្ម័គ្រតែចំពោះប្តីរបស់នាង។ រឿងនេះបានឮទៅដល់នាងស្វាហាដែលជាបុត្រីរបស់ស្តេចទក្ស និងជានារីម្នាក់ដែលបានចាប់ចិត្តលើព្រះអគ្នីតាំងពីក្មេងមក ហើយធ្លាប់សារភាពព្រះអគ្នីដែរ តែទ្រង់មិនចាប់ព្រះទ័យ។ នាងស្វាហាក៏បានប្រែក្រឡា

[៣] James 2002.

ធ្វើជាប្រពន្ធរបស់ឥសីអង្គិរសដើម្បីចូលទៅរួមមេត្រីជាមួយព្រះអគ្គី ដោយពេលដំបូងនាងប្រែក្រឡាទៅនាងសិវា លើកទីពីរប្រែក្រឡាជានាងបក្សីគ្រុឌី និងបាននិម្មិតជាប្រពន្ធឥសីជាបន្តបន្ទាប់ទៀត។ ម្ល៉ោះហើយ ទើបពេលព្រះស្កន្ទប្រសូត្រមានព្រះសិរប្រាំមួយ ដ្បិតព្រះអគ្គីបានរួមមេត្រីជាមួយនាងស្វាហាដែលប្រែក្រឡាទៅជានាងទាំងប្រាំមួយនាក់ជាប្រពន្ធឥសី ។[៤]

ដោយឡែក ក្រៅពីចម្ងាក់ដែលបានរៀបរាប់ខាងលើ អ្វីដែលយើងអាចកត់សម្គាល់ជាពិសេសបាននោះគឺ ខ្មែរបុរាណបានកត់ត្រាព្រះនាមព្រះស្កន្ទប្រៀបធៀបជាមួយអំណាចព្រះរាជាខ្មែរទៀតផងនៅក្នុងសិលាចារឹក។ ឧទាហរណ៍ សិលាចារឹកប្រាសាទភ្នំហាន់ជ័យ (K.81) (រូបលេខ ១២) ស.វ.ទី៧ គាថាទី២១ រៀបរាប់ថា[៥]៖

"នវេវយសិរ្វ្ត្តស្យ យស្យរាជ្យកពេទ្យតះ
ចិត្រិយតេកុមារស្យ សៃនាន្យំមរុតាមិវ។

ប្រែសម្រួលថា៖

"**តាំងពីនៅបឋមវ័យរហូតដល់ព្រះអង្គបានទទួលភារកិច្ចគ្រប់គ្រងដែនដី ព្រះអង្គមានព្រះតេជៈបារមី មានរស្មីភ្លឺថ្លា ប្រៀបដូចព្រះកុមារ ដែលដឹកនាំទ័ពមរុត (Maruta)។**

សិលាចារឹកនេះផ្តល់ព័ត៌មានឱ្យយើងដឹងថា មនុស្សនៅសម័យបុរាណស្គាល់ច្បាស់ថា ព្រះស្កន្ទជាទេពខាងសឹកសង្គ្រាមនិងជាមេទ័ពដ៏អស្ចារ្យនៅស្ថានសួគ៌ក្នុងលទ្ធិព្រហ្មញ្ញសាសនា។ ម្ល៉ោះហើយ ទើបបានគេចារជាកំណាព្យសំស្ក្រឹតឡើងប្រៀបប្រដូចអំណាចរបស់ព្រះរាជាដ៏ខ្លាំងក្លាដូចទេពអង្គនេះដែរ។ ពោល គឺគេប្រៀបធៀបព្រះបាទភវវរ្ម័នទី១ ដែលជាស្តេចអាណាចក្រចេនឡាសោយរាជ្យនៅរវាងឆ្នាំគ.ស.៥៩៨ ដល់ឆ្នាំ ៦០៦ ខ្លាំងក្លាដូចព្រះកុមារ ដែលជាព្រះនាមមួយរបស់ព្រះស្កន្ទ។ ជាពិសេសនោះ គឺគេស្គាល់យ៉ាងច្បាស់ថាព្រះស្កន្ទជាមេបញ្ជាការរបស់កងទ័ពមរុតដែលជាកងទ័ពដ៏សំខាន់របស់ស្ថានសួគ៌ និងជាបុត្ររបស់នាងទិតិ។[៦] ត្រង់ចំណុចនេះមានន័យថា ព្រះមហាក្សត្រនៅសម័យបុរាណប្រៀបដូចជាមេទ័ពដ៏ខ្លាំងក្លាក្នុងសឹកសង្គ្រាម ដែលតែងចូលរួមដឹកនាំទ័ពធ្វើសង្គ្រាមដោយផ្ទាល់ទៅគ្រប់ទិសទី ដូចមានរៀបរាប់នៅក្នុងគាថាផ្សេងទៀតនៃសិលាចារឹកភ្នំហាន់ជ័យនេះស្រាប់។

---

[៤] Roshen 2014.

[៥] ប្រែសម្រួលដោយ លោក កំ វណ្ណាក៏។

[៦] Muller 1891.

សិលាចារឹកមួយទៀតរកឃើញនៅវត្តហា ខេត្តព្រៃវែង ចុះបញ្ជីលេខ K.57 ចារក្នុងរាជ្យព្រះបាទយសោវរ្ម័នទី១ បានរៀបរាប់ថា៖ "***នៅមហាសករាជឆ្នាំ៨១១ ព្រះបាទស្រីយសោវរ្ម័នទី១ បានកសាងប្រាសាទមួយសម្រាប់ឧទ្ទិសដល់ព្រះស្រីកាត្តិកេយ (ព្រះស្កន្ទ)***"។[៧] សិលាចារឹកនេះបង្ហាញថានៅស.វ.ទី៩ ក្នុងរាជ្យព្រះបាទយសោវរ្ម័នទី១ (គ.ស.៨៨៩ - ៩១០) ទ្រង់ក៏មានការគោរពបូជាចំពោះព្រះស្កន្ទដូចគ្នា ដ្បិតទេពអង្គនេះជាបុត្ររបស់ព្រះសិវជាអាទិទេពធំជាងគេ។

ជារួមមក ព្រះស្កន្ទ គឺជាអាទិទេពខាងសឹកសង្គ្រាមឬចម្បាំងដ៏អស្ចារ្យក្នុងព្រហ្មញ្ញសាសនា ហើយទេពអង្គនេះ បានចាក់ដោតជ្រៅក្នុងផ្នត់គំនិតរបស់ខ្មែរបុរាណតាំងពីរវាងស.វ.ទី៦មកម៉្លេះ ដូចមានបង្ហាញជាចម្លាក់និងសិលាចារឹក។ ការកត់សម្គាល់ជាពិសេសនោះគឺ នៅសម័យបុរាណគេបានប្រៀបប្រដូចអំណាចព្រះរាជា គឺព្រះបាទភវវរ្ម័នទី១ ឱ្យដូចនឹងព្រះស្កន្ទដែលជាមេទ័ពដ៏ខ្លាំងក្លានៅស្ថានសួគ៌។ សព្វថ្ងៃ ឥទ្ធិពលព្រះស្កន្ទទៅលើសង្គមខ្មែរហាក់ថមថយចុះជាងមុនឆ្ងាយ ព្រោះបច្ចុប្បន្នយើងគោរពប្រណិប័តន៍ខ្លាំងទៅលើព្រះពុទ្ធសាសនាថេរវាទ។ ប៉ុន្តែ ពាក្យមួយដែលជាប់ទាក់ទងនឹងព្រះស្កន្ទ គឺពាក្យ "ស្កន្ទជាន់" នៅតែបន្តនិយាយមកដល់សព្វថ្ងៃ ដែលសំដៅទៅលើក្មេងដែលមានជំងឺប្រកាច់ មានអាការប្លែកៗ តឹងដើមទ្រូងផ្អើះៗ ក្តាប់ដៃក្តាប់ជើងជាដើម៕

[៧] Aymonier 1900.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី





រូបលេខ១-២៖ ចម្លាក់ព្រះស្កន្ទគង់ឈរលើក្ងោកមិនស្គាល់ប្រភព (សារមន្ទីរជាតិ) រូបថត៖ ជា សុជាតិ
រូបលេខ៣៖ ព្រះស្កន្ទគង់លើក្ងោកមកពីទួលក្ដីអង្គ ខេត្តព្រៃវែង (សារមន្ទីរហ្គីមេ) រូបថត៖ ហួន យ៉ាវ





រូបលេខ៤៖ ព្រះស្កន្ទគង់លើក្ងោកមកពីខេត្តកំពង់ចាម (សារមន្ទីរជាតិ) រូបថត៖ ជា សុជាតិ
រូបលេខ៥៖ ព្រះស្កន្ទគង់លើក្ងោកមិនស្គាល់ប្រភព (សារមន្ទីរកំពង់ធំ) រូបថត៖ ម៉ង់ វ៉ាលី
រូបលេខ៦៖ ព្រះស្កន្ទទ្រង់ឈរសំពះសុំពរព្រះឥសូរ (សារមន្ទីរជាតិ) រូបថត៖ Emma & Douglas







រូបលេខ៧៖ ព្រះស្កន្ទគង់លើក្ងោកមកពីប្រាសាទក្រចាប់ (សារមន្ទីរជាតិ) រូបថត៖ Emma & Douglas
រូបលេខ៨៖ ព្រះស្កន្ទគង់លើក្ងោកឆ្លាក់លើផ្ដែរទ្វារវត្តកកោះ រូបថត៖ ម៉ង់ វ៉ាលី
រូបលេខ៩៖ ព្រះស្កន្ទគង់លើក្ងោកឆ្លាក់ក្បែរព្រះឥសូរជិះគោនៅផ្ដែរប្រាសាទភិមាយ រូបថត៖ Nattapong





រូបលេខ១០៖ ព្រះស្កន្ទមានព្រះសិរប្រាំមួយគង់លើក្ងោកឆ្លាក់ក្បែរព្រះឥសូរជិះគោនៅពើងគំនូរ រូបថត៖ អេង តុលា
រូបលេខ១១៖ ព្រះស្កន្ទគង់លើក្ងោកឆ្លាក់ក្បែរព្រះឥសូរជិះគោនៅពើងត្បាល់ រូបថត៖ គុំ រតនៈពិសិដ្ឋ



រូបលេខ១២៖ គោលចារឹកប្រាសាទភ្នំហាន់ជ័យ (K.81)  រូបថត៖ EFEO

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

## ឯកសារយោង


*ចូ ចុន*

២០២១, *ចម្លាក់សោមស្កន្ទក្នុងសិល្បៈខ្មែរ, ផ្សាយក្នុងគេហទំព័រ* AMS Khmer Civilization https://asset.ams.com.kh/khmercivilization/media/Somaskanda-in-Khmer-Art.pdf

**Aymonier, E.**

1900, *Le Cambodge, Le Royume Actuel,* Paris

**Fred, W.C.**

1978, *The many faces of Murugan: The History and Meaning of a South Indian,* Mouton.

**James, G.L.**

2002, *The illustrated encyclopedia of Hinduism,* Rosen Publishing Group.

**Muller, M.**

1891, *Vedic Hymns,* Part 1: Clarendon Press

**Roshen, D.**

2014, *Hinduism: an alphabetical guide,* Penguin UK.

**Roveda, V.**

2005, *Image of the Gods,* River Books: Bangkok

**Vanita, R & Kidwai, S.**

2001, *Same Sex Love India: Readings from Literature and History*, Palgrave Macmillan